# ដំរីស

តាមវចនានុក្រមសម្ដេច **ជួន ណាត** ពាក្យថា ផៀក ឬ ឃៀច គឺសំដៅទៅលើមនុស្ស ឬសត្វដែលមានសម្បុរសខុសប្រក្រតី គឺមានស្បែកស, រោមស, សក់ស, រោមភ្នែកស តាំងពីកំណើត (ពាក្យជាភាសាអង់គ្លេសហៅថា albino = a person or animal whose skin and hair lack pigmentation)។



ចំពោះសត្វដំរីឃៀច អ្នកផងគេនិយមហៅថា ដំរីស។ តាំងពីបុរាណកាលមក ដំរីសត្រូវគេចាត់ទុកជាសត្វមានតម្លៃទើបមហាក្សត្រនានាកាលសម័យដើមតែងចង់បានយកមកធ្វើជាយានជំនិះដំរុងរឿងរបស់ខ្លួន។



ដំរីសជាព្រះទីនំងនៃព្រះរាជា - ប្រទេសភូមា

រឿងនិទានផ្សេងៗ បានតម្កើងដំរីសជាស្ដេចលើអស់ដំរី ថែមទាំងមានឫទ្ធិបារមីដូចទេវតាទៀតផង ដូចជារឿង **នាងកន្ធង់សុគ្រា - កូនស្ដេចដំរីស** ជាដើម។

**ព្រះវេស្សន្តរ** ក៏មានដំរីសជាព្រះទីន័ង ដែលរាស្ត្រប្រជាជឿថាជាសត្វនាំមកនូវសិរីសួស្ដីដល់ព្រះនគរ លុះព្រះវេស្សន្តរធ្វើទានដំរីសនោះដល់រាស្ត្រនគរដទៃ នគររបស់ទ្រង់ក៏ជួបប្រទះភាពរាំងស្ងួតនិងទុរភិក្ស រហូតដល់រាស្ត្របះបោរ ទាមទារឱ្យនិរទេសព្រះវេស្សន្តរចេញពីព្រះបរមរាជវាំង។



ដំរីសជាទីនំងព្រះវេស្សន្តរ - ប្រទេសថៃ?



ដំរីសដែលព្រះវេស្សន្តរបានប្រទានឱ្យដល់អ្នកមកសូមទានព្រះអង្គ - វត្តកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង

ឯរឿងដំណាលមួយទៀតមានសេចក្ដីថា កាលពីព្រះអង្គម្ចាស់ ច័ន្ទរាជា រត់ទៅជ្រកកោននៅប្រទេសសៀម ក្រោយការជ្រែករាជ្យរបស់ស្ដេចកន (ឆ្នាំ១៥១២ គ.ស) ព្រះអង្គម្ចាស់អាចនាំពលសេនានិងស្បៀងអាហារត្រលប់មកធ្វើសង្គ្រាមដណ្ដើមរាជ្យពីស្ដេចកនឯស្រុកខ្មែរវិញបាន ក៏ព្រោះតែព្រះអង្គបោកកុហកស្ដេចសៀមថាទ្រង់ត្រូវការពលសេនានិងស្បៀងអាហារដើម្បីចូលទៅទាក់ស្ដេចដំរីសពីក្នុងព្រៃជ្រៅ មកថ្វាយព្រះចៅសៀម។

ដំរីសក៏ត្រូវបានគេយកទៅដាក់ជាឈ្មោះវត្តអារាមផងដែរ ដូចជា **វត្តដំរីស** នៅក្រុងបាត់ដំបង និងនៅស្រុករការកោង ខេត្តកណ្ដាលជាដើម។ រីឯភ្លេងបុរាណខ្មែរ ក៏មានឈ្មោះថា **បទដំរីស** មួយមេដែរ ដែលមានបទមួយរាយទំនុកពិរោះរណ្ដំគួរស្រណោះស្រណោកដូចខាងក្រោម៖

# ដំរីស

ដំរីសអើយ ដំរីសសត្វ
អ្នកមានវិបត្តិព្រោះព្រាត់សង្សារ
ដំរីសញីអើយតើនៅទីណា
ឱ្យឈ្មោលទុក្ខាខ្លោចផ្សាចំបែង
ព្រាត់ដោយល្បិចកលឬដោយផលព្រេង
ឬមួយវង្វេងនៅក្នុងព្រឹក្សព្រៃ។



ឬមួយត្រូវព្រានចិត្តអន្យតិរ្ថិយ
ទាក់នាងដំរីប្រល័យសង្ខារ
ដំរីឈ្មោលអើយកើតទុក្ខយ៉ាងណា
ជាសត្វម្រឹគាចេះឈឺចាប់ទេ
ខ្ញុំជឿខ្ញុំយល់ថាអ្នកខ្វល់ដែរ
មិនខុសគ្នាទេថ្វីបើជាសត្វ។



រឿងខ្ញុំនិងអ្នកហាក់ដូចតែគ្នា
ខ្ញុំក៏គ្រាំគ្រាដូចជាអ្នកដែរ
សង្សារខ្ញុំមួយត្រូយពន្លកស្នេហ៍
ស្រលាញ់ម្ល៉េះទេប៉ុន្តែឃ្លាតបាន
ចិត្តនឹករាល់ថ្ងៃស្ទើរក្ស័យប្រាណ
នាំរឿងរំខានមិនបានសុខសោះ។

អ្នកជាសត្វផងគង់អ្នកស្រណោះ
ចំណង់បើមនុស្សតើយ៉ាងណាទៅ
ខ្ញុំស្ទើរតែឆ្កួតរហូតឥឡូវ
ក្នុងទ្រូងហ្មងសៅក្ដៅក្តួលឈឺផ្សា
ដំរីសអើយល្មមឈប់សោកា
នេះជាវាសនារបស់យើងទេ។

សិល្បករ៖ ស៊ិន ស៊ីសាមុត

Khmer Story Lovers